# អារម្មណ៍ដ៏ជ្រាលជ្រៅ ក្នុងរឿងភាពយន្ត"សំបុត្រស្នេហ៍ជូនលោកយាយ"

តាមពិតទៅ អ្នកដឹកនាំរឿងឈ្មោះ ឡាន ហុងឈុន មិនមានការរំពឹងទុកខ្ពស់ចំពោះភាពយន្ត "សំបុត្រស្នេហ៍ជូនលោកយាយ" (Dear You) ទេ ដែលប្រើថវិកាត្រឹមតែ ១៤ លានយ៉ាន់ តួសម្តែងមិនល្បីឈ្មោះ និងមានការសន្ទនាជាគ្រាមភាសាឆាវសាន។ ទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពីការចាក់បញ្ចាំងជាសាធារណៈ វាបានក្លាយជាសេះខ្មៅដ៏ធំបំផុតក្នុងអំឡុងថ្ងៃឈប់សម្រាកទិវាពលកម្មអន្តរជាតិ។ ប្រាក់ចំណូលពីការលក់សំបុត្របានមានចំនួនលើសពី ៥០០ លានយ៉ាន់ ដោយមានទស្សនិកជនជាង ៤៥% មកពីខាងក្រៅតំបន់ឆាវសាន។ យុវជនយុវនារីបានដើរចូលក្នុងរោងភាពយន្តដើម្បីទស្សនារឿងរ៉ាវអំពីអាណិកជនចិនដ៏គួរជាទីចាប់អារម្មណ៍នេះ។ ហេតុអ្វីបានជាសំបុត្រមួយច្បាប់អាចទាក់ទាញក្រសែភ្នែករបស់មនុស្សជាច្រើន?



## កាន់តែអត់ធ្មត់ កាន់តែមានភាពខ្លាំងក្លា

រសជាតិរបស់យុវវ័យជំនាន់នេះបានផ្លាស់ប្តូរហើយ។ តើខ្សែភាពយន្តមួយដែលថតជាគ្រាមភាសា ឆាវសាន និងនិទានរឿងរ៉ាវយឺតៗ អាចទាក់ទាញចំណាប់អារម្មណ៍របស់អ្នកទស្សនាបានរយៈពេល ២ ម៉ោងដោយរបៀបណា?

គេបានវាយតម្លៃតាមអ៊ីនធឺណិតថា ពាក់កណ្តាលដំបូងនៃរឿងនេះមានភាពសាមញ្ញ ហើយខ្ញុំមានអារម្មណ៍ថាវាមិនសមនឹងការសរសើរខ្ពស់បែបនេះទេ។ ប៉ុន្តែខ្ញុំកាន់តែត្រូវបានទាក់ទាញនៅពេលមើលជាបន្ត ហើយធ្វើឱ្យខ្ញុំមានចំណាប់អារម្មណ៍ខ្លាំងបំផុត។

ចំណាប់អារម្មណ៍បែបនេះកើតចេញពីភាពអត់ធ្មត់ពិសេសដែលមាននៅក្នុងវប្បធម៌តំបន់ឆាវសាន។ អ្នកនិពន្ធវ័យក្មេងឈ្មោះ ឆឹន យូនធីង បាននិយាយថា ជីដូនជីតារបស់ខ្ញុំគឺកើតនៅជំនាន់នេះ។ សូម្បីតែប្រឈមមុខនឹងបញ្ហាធំប៉ុនណាក៏ដោយ ក៏ពួកគាត់តែងមានអារម្មណ៍ធូរស្រាល។ ប៉ុន្តែនៅពីក្រោយអារម្មណ៍ធូរស្រាលនោះ អ្នកអាចយល់ថាបានបង្កប់នូវអ្វីដែលមានអត្ថន័យដ៏ជ្រាលជ្រៅនៅក្នុងក្រអៅបេះដូងរបស់ពួកគេ។

ភាពអត់ធ្មត់បែបនេះអាចនាំមកនូវគ្រោះថ្នាក់ដល់អាយុជីវិត។ នៅពេលដែលលោកយាយ យឺ ស៊ូយូវ បានដឹងថាស្វាមីរបស់គាត់បានទទួលមរណភាពនៅឯស្រុកឆ្ងាយជាយូរមកហើយនោះ លោកយាយ សៀ ណានជី ដែលមានវ័យចំណាស់ក៏បានមកសាកសួរសុខទុក្ខលោកយាយដោយភាពក្តុកក្តួលក្នុងចិត្ត ប៉ុន្តែលោកយាយមិនបានយំស្រែកខ្លាំងៗទេ។ គាត់គ្រាន់តែកាន់រូបថត "ក្លែងក្លាយ" នោះដោយស្ងប់ស្ងាត់ ហើយបន្ទាប់មកនិយាយយ៉ាងស្រទន់ថាបន្លែអូលីវប្រហែលជាត្រជាក់ហើយ។ បន្ទាប់មក គាត់បានងាកទៅក្រោយដោយស្ងៀមស្ងាត់ ហើយដើរចូលទៅក្នុងផ្ទះបាយដែលមានពន្លឺស្រអាប់។

មិនមានតន្ត្រីគួរជាទីរំជួលចិត្ត ហើយក៏មិនមានឈុតឆាកយំបំផ្លើសដែរ។ គ្រាន់តែពាក្យមួយម៉ាត់ដែលថា "បន្លែអូលីវប្រហែលជាត្រជាក់ហើយ" បានទាក់ទាញអារម្មណ៍របស់យុវជនច្រើនរាប់មិនអស់។ អ្នកខ្លះបានថ្លែងចំណាប់អារម្មណ៍ថា មិនមែនដោយសារតែភាពយន្តនេះល្អមើលនោះទេ ប៉ុន្តែយើងចង់បានសេចក្តីស្រឡាញ់ពិតប្រាកដបែបនេះខ្លាំងពេកហើយ។



## ធូលី និងដីនៅក្នុងសំបុត្រអាណិកជនចិន

មនោសញ្ចេតនាបែបនេះ ត្រូវបានបង្កប់នៅក្នុងក្រដាសពណ៌លឿងចាស់ៗទាំងនោះ ដែលត្រូវបានមនុស្សជំនាន់ក្រោយហៅថា "សំបុត្រអាណិកជនចិន"។

នៅក្នុងគ្រាមភាសាឆាវសាន "សំបុត្រ" ត្រូវបានហៅថា "ភី"។ នៅឆ្នាំ ១៨៨១ ជនជាតិចិនដែលធ្វើចំណាកស្រុកម្នាក់ឈ្មោះ យី ហ៊ឺយ៉ុន បានសរសេរសំបុត្រទៅកាន់ម្តាយរបស់គាត់ថា ឥឡូវនេះ ខ្ញុំទើបតែមកដល់ទីកន្លែងថ្មីនេះហើយ គ្រប់យ៉ាងមិនទាន់ដឹងច្បាស់នៅឡើយទេ...ចាំមើលថាអ្វីៗនឹងប្រែជាយ៉ាងណានៅឆ្នាំក្រោយ..." ពាក្យ ២-៣ ម៉ាត់នេះបានបង្ហាញពីការលំបាក និងការសោកស្តាយរបស់គាត់នៅពេលដំបូងដែលធ្វើដំណើរទៅដល់តំបន់អាស៊ីអាគ្នេយ៍។

នៅមានមនុស្សម្នាក់ឈ្មោះ ឆឹន ជួនយូយ ដែលបានសរសេរតួអក្សរធំមួយ "难" (ពិបាក) នៅចំកណ្តាលសំបុត្ររបស់គាត់ ដោយបញ្ជាក់ជាកំណាព្យមួយនៅខាងឆ្វេងថា "ទៅស្រុកកំណើតមានផ្លូវវែងឆ្ងាយ មានអារម្មណ៍នឹករលឹកទាំងយប់ទាំងថ្ងៃ"។ របៀបសម្តែងអារម្មណ៍បែបនេះអាចធ្វើឱ្យយើងទាំងអស់គ្នាចាប់អារម្មណ៍យ៉ាងខ្លាំង។ តាមពិតទៅ វាមានរឿងរ៉ាវជាច្រើនអំពីសំបុត្រអាណិកជនចិន។ នៅក្នុងសម័យកាលដ៏ច្របូកច្របល់ដែលគ្មានប្រព័ន្ធប្រៃសណីយ៍ សំបុត្រអាណិកជនចិនត្រូវបានដឹកជញ្ជូនដោយ "អ្នកនាំសារ" ផ្ទាល់។ ទោះបីជាអ្នកនាំសារទាំងនេះក្រីក្រ ហើយបានប្រាក់តិចតួចក៏ដោយ ក៏ប៉ុន្តែពួកគេមិនដែលកេងប្រាក់ដែលអាណិកជនចិនផ្ញើទៅគ្រួសារនោះឡើយ។ នៅឯការិយាល័យផ្ញើប្រាក់ ហ្វូឆឹង ចាស់ក្នុងឃុំឡុងទូ ស្រុកឆឹងហៃនៅតែឆ្លាក់អក្សរចិនថា "នៅពេលឃើញផលប្រយោជន៍ ត្រូវគិតអំពីសុចរិតភាព" និង "នៅពេលដឹងខុស ត្រូវតែកែតម្រូវកំហុសរបស់ខ្លួន"។ ពាក្យទាំងពីរនេះគឺជាគោលការណ៍រក្សាកិត្តិនាមនៅក្នុងសម័យនោះ ដែលជាសសរទ្រទ្រង់សម្រាប់មនុស្សជំនាន់នោះក្នុងការធ្វើចំណាកស្រុកដើម្បីរកស៊ីនៅឯស្រុកឆ្ងាយ។

## ពាក្យ "អរគុណ" ដែលមិនបាននិយាយ

តើយុវវ័យត្រូវបានទាក់ទាញដោយអ្វី? បន្ទាប់ពីមើលភាពយន្ត អ្នកទស្សនាជាច្រើនបានបញ្ចេញមតិតាមអ៊ីនធឺណិតថា ពិតជាមានចំណាប់អារម្មណ៍ខ្លាំងណាស់។ ការយំបែបនេះមិនមែនដោយសារការឡើងចុះយ៉ាងខ្លាំងក្នុងឆាកជីវិតនោះទេ ប៉ុន្តែកើតចេញពីមនោសញ្ចេតនារួមគ្នា។

អ្នកខ្លះបាននិយាយថា ខ្ញុំបានទៅរកមើលរូបថតចាស់របស់ជីដូនខ្ញុំភ្លាមៗបន្ទាប់ពីមើលភាពយន្តនេះ ហើយសួរម្តាយខ្ញុំថា តើរូបថតនេះថតដោយអ្នកណា? និស្សិតមកពីទីក្រុងឆឹងទូដែលមានអាយុ ២២ ឆ្នាំម្នាក់ បាននិយាយថា ខ្ញុំក៏ដូចចៅប្រុសឈ្មោះ សៀវវ៉ៃ ក្នុងភាពយន្តនេះដែរដែលតែងតែគិតថានៅមានពេលវេលាច្រើន ប៉ុន្តែខ្ញុំភ្លេចថាជីដូនរបស់ខ្ញុំមានសក់ស្កូវកាន់តែច្រើនឡើងៗពីមួយថ្ងៃទៅមួយថ្ងៃ។

ក្នុងខ្សែភាពយន្តនេះលោកយាយ សៀ ណានជី បានសរសេរសំបុត្រក្លែងក្លាយសម្រាប់អ្នកភូមិដែលបានស្លាប់អស់រយៈពេល ១៨ ឆ្នាំ ដោយបោកបញ្ឆោតស្ត្រីដែលបានរង់ចាំយ៉ាងវេទនានៅក្នុងស្រុកកំណើត។ ដោយប្រឈមមុខនឹងសំណួររបស់កូនចៅគាត់គ្រាន់តែញញឹមនៅស្ងៀម ហើយមិនបាននិយាយអ្វីសោះឡើយ។

លោក ឡាន ហុងឈុន បានទៅមើលសំបុត្រអាណិកជនចិនរាប់ពាន់ច្បាប់។ គាត់បាននិយាយថា ប្រសិនបើអ្នកយល់ថាអ្វីដែលខ្ញុំបាននិយាយនោះគួរឱ្យធុញ សូមប្រាប់ខ្ញុំផង ពីព្រោះខ្ញុំមិនចង់ឱ្យទស្សនិកជនមានអារម្មណ៍ធុញទ្រាន់សូម្បីតែមួយវិនាទី។

យុវជនជំនាន់នេះចាប់ផ្តើមគិតគូរពីការប្រើប្រាស់ក្រដាសដើម្បីសម្តែងមនោសញ្ចេតនានៅក្នុងសម័យកាលនៃពាក្យផ្អែមល្ហែមដែលបង្កើតឡើងដោយ AI និងភាពព្រងើយកន្តើយក្នុងសង្គម។ ក្រុមមនុស្សជំនាន់ Z (Gen Z) ដែលធ្លាប់តែប្រកាសថាចង់ "កាត់ផ្តាច់ទំនាក់ទំនងគ្រួសារ" នោះ ពេលនេះបានឃើញច្បាស់នូវខ្សែស្រឡាយសាច់ឈាមរបស់ពួកគេ តាមរយៈសក់ស្កូវនៅលើក្បាលរបស់លោកយាយ។

នៅល្ងាចដែលភាពយន្ត "សំបុត្រស្នេហ៍ជូនលោកយាយ" រកចំណូលបានជាង ៥០០ លានយ៉ាន់ក្នុងការលក់សំបុត្រ លោក ឡាន ហុងឈុន ដែលជាអ្នកដឹកនាំរឿងនេះ បានសរសេរថា សូមអរគុណអ្នកទាំងអស់គ្នា ហើយអ្នកទាំងអស់គ្នាក៏ជាផ្នែកមួយនៃសំបុត្រស្នេហ៍នេះដែរ។

នេះគឺជាការឆ្លើយតបរបស់ប្រជាជនមកពីតំបន់ឆាសាន។ ពាក្យពេចន៍រាប់មិនអស់ដែលលាក់ទុកនៅក្នុងជីវិតប្រចាំថ្ងៃ និងអារម្មណ៍នឹករលឹកដែលយើងធ្លាប់មើលរំលងទាំងនោះគួរតែទទួលបាននូវការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅអំពីយើងខ្ញុំ៕

Mekong News Network

http://www.yunnangateway.com/

អ្នកនិពន្ធភាសាខ្មែរ៖ LI ZHA SHEN YAN LI MENGLI រចនារូបភាព៖ SUN YONGGANG